ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម
លេខ ១៩៧ សណ៣ ធទឧ

# សេចក្តីជូនដំណឹង

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការសង្កេត និងតាមដានលើស្ថានភាពអាកាសធាតុរួចមក ឃើញថា : ចាប់ពីថ្ងៃទី 26 ដល់ថ្ងៃទី 29 ខែកក្កដា ឆ្នាំ 2011 ព្រះរាជាណាចក្រកម្ពុជានឹងទទួលឥទ្ធិពលពីប្រព័ន្ធសម្ពាធទាប ( ITCZ ) ។ ស្ថានភាពបែបនេះនឹងបង្កឱ្យ :

- **តំបន់មាត់សមុទ្រ** : មានភ្លៀងធ្លាក់ខ្លាំង និងអាចបង្កឱ្យមានជំនន់ទឹកភ្លៀងនៅផ្នែកខ្លះនៃខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត ព្រមទាំងកំណាត់ផ្លូវជាតិលេខ 4 ។
- **តំបន់ខ្ពង់រាបភាគឦសាន**: មានភ្លៀងធ្លាក់ខ្លាំង និងអាចបង្កឱ្យមានជំនន់ទឹកភ្លៀងនៅផ្នែកខ្លះនៃខេត្តស្ទឹងត្រែង ក្រចេះ រតនគិរី និងខេត្តមណ្ឌលគិរី ។
- **តំបន់វាលទំនាបកណ្តាល** : មានភ្លៀងធ្លាក់ក្នុងកម្រិតមធ្យម ។

ឥទ្ធិពលនៃប្រព័ន្ធសម្ពាធទាបនេះ ក៏នឹងធ្វើឱ្យកំពស់ទឹកទន្លេមេគង្គហក់ឡើងផងដែរ ។

យោងតាមសភាពការណ៍ធាតុអាកាសខាងលើ ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់អាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេមេគង្គ និងតាមបណ្តាខេត្តដូចបានជម្រាបជូនខាងលើ សូម**បង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្ន** ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

*រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១១*

**រដ្ឋមន្ត្រី**

**លឹម គានហោ**